**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈទន្តពេទ្យកម្ពុជា**
**ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**
លេខ០០២៧/១៥.......កទជ

ភ្នំពេញ ថ្ងៃទី២០.....ខែ.មេសា.......ឆ្នាំ២០១៥

# សេចក្តីសម្រេច
## ស្តីពី
## ប្រាក់ភាគទានសមាជិកភាព

## ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣៥៦.អនក្រ.តត ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ
- បានឃើញសេចក្តីសម្រេចលេខ ០០១៩/១៥ កទជ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីបទបញ្ជាផ្ទៃក្នុងគណៈទន្តពេទ្យកម្ពុជា
- តាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១.~**

ទន្តពេទ្យ នៅពេលសុំចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យកម្ពុជា ត្រូវបង់ប្រាក់ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដែលខ្លួនតាំងនៅប្រកបវិជ្ជាជីវៈ នូវសិទ្ធិចុះឈ្មោះជាសមាជិក ចំនួន២០០.០០០រៀល (ពីររយពាន់រៀល)ស្របតាមមាត្រា៣៦ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា។

ប្រការ ២.~

នៅពេលបានចូលជាសមាជិកគណៈទន្តពេទ្យហើយ សមាជិកម្នាក់ៗមានកាតព្វកិច្ចបង់ប្រាក់ភាគទានប្រចាំឆ្នាំ ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត នីមួយៗ ដូចមានចែងខាងក្រោមៈ

ក.រាជធានីភ្នំពេញ ត្រូវបង់ប្រាក់ភាគទានប្រចាំឆ្នាំ ជូនគណៈទន្តពេទ្យ ចំនួន៣០០.០០០រៀល(បីរយពាន់រៀល)។

ខ.ខេត្តកណ្ដាល ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ត្រូវបង់ប្រាក់ភាគទានប្រចាំឆ្នាំ ជូនគណៈទន្តពេទ្យចំនួន ២៤០.០០០រៀល (ពីរយសែសិបពាន់រៀល)។

គ.ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តកែប ខេត្តព្រះវិហារ ខេត្តមណ្ឌលគីរី ខេត្តរតនៈគីរី ខេត្តប៉ៃលិន ត្រូវបង់ ប្រាក់ភាគទានប្រចាំឆ្នាំ ជូនគណៈទន្តពេទ្យចំនួន ១២០.០០០រៀល(មួយរយម្ភៃពាន់រៀល)។

ប្រការ ៣.~

ទន្តពេទ្យបរទេសទាំងអស់ ដែលមានបំណងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវមកសុំចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យកម្ពុជា។នៅពេលសុំចុះឈ្មោះ ទន្តពេទ្យបរទេស ត្រូវបង់ប្រាក់ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដែលខ្លួនតាំងនៅប្រកបវិជ្ជាជីវៈនូវសិទ្ធិចុះឈ្មោះជាសមាជិកចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) និងប្រាក់ភាគទានប្រចាំឆ្នាំចំនួន ១.២០០.០០០រៀល(មួយលានពីររយពាន់រៀល)។

ប្រការ ៤.~

ទន្តពេទ្យបរទេសទាំងឡាយ ដែលមានបំណងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជារយៈពេលខ្លី ចាំបាច់ត្រូវមកសុំចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យជាតិ ដើម្បីទទួលបានលិខិតអនុញ្ញាតិប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និង ត្រូវបង់ប្រាក់ភាគទាន ដូចមានចែងខាងក្រោម៖

ក.០១(មួយ)ថ្ងៃដល់៣០(សាមសិប)ថ្ងៃត្រូវបង់ប្រាក់ភាគទានចំនួន២៤០.០០០រៀល(ពីរយសែសិបពាន់រៀល)

ខ. លើស០១(មួយ)ថ្ងៃ ត្រូវបង់ប្រាក់ភាគទាន ចំនួន២៤០.០០០រៀល(ពីរយសែសិបពាន់រៀល) បន្ថែម

គ.លើស១៨០(មួយរយប៉ែតសិប)ថ្ងៃក្នុងមួយឆ្នាំ ត្រូវសុំចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យរាជធានីខេត្ត ដែលខ្លួនតាំងនៅប្រកបវិជ្ជាជីវៈ។

ប្រការ ៥.~

ទន្តពេទ្យបរទេស ដែលបានផ្តល់គុណប្រយោជន៍ក្នុងវិស័យទន្តសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា អាចទទួលបានការអនុគ្រោះ លើប្រាក់សុំចុះឈ្មោះ និង/ឬប្រាក់ភាគទានប្រចាំឆ្នាំ តាមការសម្រេចរបស់ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ៦.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ រាជធានី ខេត្ត មានតួនាទីអនុវត្តសេចក្តីសម្រេចនេះ។

**ប្រការ ៧.~**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.~**

សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ. ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**

**ប្រធាន**

DENTAL COUNCIL OF CAMBODIA

**ឯកឧត្តម.សុខុម_រិទ្ធីវុធ**

កន្លែងទទួល៖

-ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

-ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ

-ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ